# ទិវាសត្វព្រៃពិភពលោក៖ អង្គការសត្វព្រៃ និងក្រសួងអំពាវនាវឲ្យពលរដ្ឋបញ្ឈប់ការបរិភោគសាច់សត្វព្រៃ ដោយបារម្ភខ្លាចឆ្លងជំងឺផ្សេងៗ

http://www.rfi.fr/km/cambodia/wild-animal-day-03-03-2020



ថ្ងៃទី៣ ខែមីនានេះ គឺជាទិវាសត្វព្រៃពិភពលោក។ ក្រសួងបរិស្ថាន និងអង្គការមូលនិធិសកលសម្រាប់អភិរក្សធនធានធម្មជាតិ ហៅកាត់ថា WWF បានអំពាវនាវឲ្យមាន ការការពារជីវិតសត្វព្រៃ ជីវៈចម្រុះ និងធនធានធម្មជាតិ ជាពិសេសមិនត្រូវបរិភោគសាច់សត្វព្រៃ។ សាច់សត្វព្រៃ ដែលអាចបង្កជាជំងឺផ្សេងៗ ដូចករណីជំងឺកូវីដ១៩ ដែលអាចឆ្លងមកពីសត្វព្រៃ។

តាមរយៈទំព័រហ្វេសប៊ុកផ្លូវការរបស់ខ្លួនអង្គការមូលនិធិសកលសម្រាប់អភិរក្សធនធានធម្មជាតិ (WWF) ក្នុងឱកាសទិវាសត្វព្រៃពិភពលោកបានលើកឡើងជាសារបែបអប់រំ និងអំពាវនាវឲ្យមានការចូលរួមការពារជីវិតសត្វព្រៃ ជីវៈចម្រុះ និងធនធានធម្មជាតិនានាប្រកបដោយនិរន្តរភាព។ យើងអាចចូលរួមការពារធនធានធម្មជាតិទាំងអស់នេះបានដោយ មិនបរិភោគសាច់សត្វព្រៃ ចូលរួមដាំដើមឈើឱ្យបានច្រើន កាត់បន្ថយការប្រើប្រាស់ប្លាស្ទិក និងសកម្មភាពបរិស្ថានផ្សេងៗទៀត។

លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាអ្នកនាំពាក្យ បានអះអាងប្រាប់វិទ្យុបារាំងអន្តរជាតិថា កម្ពុជាមិនបានរៀបចំព្រឹត្តិការណ៍អ្វីធំដុំនោះទេ ទាក់ទងនឹងទិវាសត្វព្រៃពិភពលោក ប៉ុន្តែការងារអភិរក្ស ការពារសត្វព្រៃនេះ គឺបន្តធ្វើជានិច្ចតាមរយៈការផ្សព្វផ្សាយ

ក៏ដូចជាការងារអភិរក្សនៅក្នុងតំបន់ការពារធម្មជាតិ ដែលមានមន្ត្រីឧទ្យានុរក្ស ១ ២៦០នាក់ នៅតាមតំបន់ការពារធម្មជាតិនានា ដើម្បីទប់ស្កាត់ និងបង្ក្រាបការបរបាញ់សត្វព្រៃ។

អ្នកនាំពាក្យក្រសួងបរិស្ថានរូបនេះ បានអំពាវនាវឲ្យប្រជាពលរដ្ឋបញ្ឈប់នូវការបរិភោគសាច់សត្វព្រៃ ដោយសារតែសាច់សត្វព្រៃគ្មានការគ្រប់គ្រង ឬត្រួតពិនិត្យឲ្យបានច្បាស់លាស់ ពីគុណភាព សុវត្ថិភាព ឬសុខភាពរបស់សត្វទាំងនោះទេ។ ជៀសវាងពីការបរិភោគសាច់សត្វព្រៃ ដើម្បីកុំឲ្យមាននូវជំងឺ ឬគ្រោះថ្នាក់ផ្សេងៗដល់សុខភាព។

លោក នេត្រ ភក្ត្រា បាន លើកឡើងថា ថ្មីៗនេះ មានការឆ្លងនូវជំងឺកូវីដ១៩ ដែលជំងឺនេះ កើតឡើងដោយវីរុស ដែលអាចមានការចម្លងពីសត្វព្រៃមក ដូច្នេះ ដើម្បីបង្ការកុំឲ្យមានការរងគ្រោះណាមួយ ប្រជាពលរដ្ឋត្រូវបញ្ឈប់ការបរិភោគសាច់សត្វព្រៃជាអាហារ។

នាយកគ្រប់គ្រងអង្គការ WWF ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកតាមរយៈសេចក្តីប្រកាស កាលពីថ្ងៃទី១ ខែមីនា បានលើកឡើងថា ប្រទេសអាស៊ីអាគ្នេយ៍គួរតែរៀនពីប្រទេសចិន ក្នុងការបញ្ឈប់ការជួញដូរសាច់សត្វព្រៃ ដើម្បីការពារសុខភាពប្រជាជន និងកុំឲ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ច ជាក់ស្តែងដូចអ្វី ដែលកំពុងកើតឡើងនាពេលនេះ គឺករណីជំងឺឆ្លងកូវីដ១៩។

សូមជម្រាបជូនថានៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ មហាសន្និបាតអង្គការសហប្រជាជាតិបានប្រកាសយកថ្ងៃទី៣ ខែមីនា ជាទិវាសត្វព្រៃពិភពលោក ដើម្បីអបអរ និងលើកកម្ពស់ការយល់ដឹងអំពីសត្វព្រៃនិងរុក្ខជាតិ៕

**សំណួរ ៖**

1. ឯកសារសំឡេងនិយាយអំពីអ្វី?
2. ទិវាសត្វព្រៃពិភពលោកប្រព្រឹត្តទៅនៅថ្ងៃណា?
3. តើអង្គការ WWF មានតួនាទីអ្វី?
4. តើយើងធ្វើដូចម្តេចដើម្បីចូលរួមទិវាសត្វព្រៃពិភពលោក?
5. តើនៅប្រទេសកម្ពុជាមានឧទ្យានុរក្សប៉ុន្មាននាក់? ពួកគាត់មានតួនាទីអ្វីខ្លះ?
6. មូលហេតុអ្វីខ្លះដែលយើងមិនគួរបរិភោគសាច់សត្វព្រៃ?
7. ហេតុអ្វីបានជាយើងត្រូវចូលរួមអភិរក្សសត្វព្រៃ?
8. ដើម្បីការពារជីវិតសត្វព្រៃតើយើងត្រូវធ្វើអ្វីខ្លះ?